# Social Due Diligence Report

November 2021

# Cambodia: Second Greater Mekong Subregion Corridor Towns Development Project

## CW01 Kampot Wastewater Collection and Treatment, and Drainage and Sewerage: VO3 Further Rehabilitation of Existing Open Canal Line 4b

(Annex E translation to Annex F)

Prepared by the Ministry of Public Works and Transport for the Asian Development Bank.

## ABBREVIATIONS

| | |
|---|---|
| ADB | Asian Development Bank |
| AHs | Affected Households |
| APs | Affected Persons |
| DED | Detailed Engineering Design |
| DMS | Detailed Measurement Survey |
| DRP | Detailed Resettlement Plan |
| EMP | Environmental Management Plan |
| GDR | General Department of Resettlement |
| GRM | Grievance Redress Mechanism |
| IOL | Inventory of Losses |
| IR | Involuntary Resettlement |
| IRC | Inter-ministerial Resettlement Committee |
| IRC-WG | Inter-ministerial Resettlement Committee Working Group |
| IRP | Income Restoration Plan |
| LAR | Land Acquisition and Resettlement |
| MPWT | Ministry of Public Works and Transport |
| PDPWT | Provincial Department of Public Works and Transport |
| PGRC | Provincial Grievance Redress Committee |
| PIB | Public Information Brochure |
| PIU | Project Implementation Unit |
| PMU | Project Management Unit |
| PISCB | Project Implementation Supervision Capacity Building |
| PPTA | Project Preparatory Technical Assistance |
| PRSC | Provincial Resettlement Sub-committee |
| PRSC-WG | Provincial Resettlement Sub-Committee Working Group |
| RCS | Replacement Cost Study |
| RGC | Royal Government of Cambodia |
| RF | Resettlement Framework |
| ROW | Right-of-Way |
| RP | Resettlement Plan |
| SES | Socioeconomic Survey |
| SOP | Standard Operating Procedures |
| SPS | Safeguards Policy Statement |
| WWTP | Wastewater Treatment Plant |

## NOTES

(i) The fiscal year (FY) of the Government of Cambodia ends on 31 December.
(ii) In this report '$" refers to US dollars.

This social due diligence report is a document of the borrower. The views expressed herein do not necessarily represent those of ADB's Board of Directors, Management or Staff, and may be preliminary in nature. Your attention is directed to the "terms of use" section on ADB's website.

In preparing any country program or strategy, financing any project, or by making any designation of or reference to a particular territory or geographic area in this document, the Asian Development Bank does not intend to make any judgments as to the legal or other status of any territory or area.

**TABLE OF CONTENTS**

I. PROJECT AND SUBPROJECT DESCRIPTION ........................................................ 5
II. INFORMATION DISCLOSURE, CONSULTATION AND PARTICIPATION ................. 11
III. DUE DILIGENCE REVIEW ........................................................................ 12
A. Objectives of Due Diligence ........................................................................ 12
B. Methodology ................................................................................................ 13
C. Scope and Nature of Impacts ....................................................................... 13
IV. GRIEVANCE REDRESS MECHANISM ..................................................... 21
V. CONCLUSIONS AND RECOMMENDATIONS ............................................... 21

# បច្ចុប្បន្នភាពប័ណ្ណព័ត៌មានសាធារណៈ
# គម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ ( GMS2 )
# អនុគម្រោង៖ ប្រព័ន្ធប្រមូលនិងប្រព្រឹត្តកម្មសម្អាតទឹកកករខ្វក់ និងប្រព័ន្ធលូរំដោះទឹកភ្លៀងនិងទឹកកខ្វក់ ( VO3 ) និងការស្តារឡើងវិញបន្ថែមនៃប្រលាយដែលមានស្រាប់( ខ្សែទី៤ខ/line4b )
# ក្រុងកំពត

-------

ប័ណ្ណព័ត៌មានសាធារណៈ (PIB) នេះរៀបចំឡើងក្នុងគោលបំណងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងគម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS2) ជូនដល់ប្រជាពលរដ្ឋ គ្រួសារ និងសហគមន៍ស្ថិតនៅទីតាំងអនុគម្រោងការស្តារឡើងវិញបន្ថែមនៃប្រឡាយដែលមានស្រាប់ (ខ្សែទី៤ខ/line 4b)។ បច្ចុប្បន្នភាពប័ណ្ណព័ត៌មាននេះ ត្រូវបានរៀបចំឡើងសម្រាប់តែអនុគម្រោងប្រព័ន្ធប្រមូលនិងប្រព្រឹត្តកម្មសម្អាតទឹកកកខ្វក់ និងប្រព័ន្ធលូរំដោះទឹកភ្លៀងនិងទឹកកខ្វក់ (VO3) និងការស្តារឡើងវិញបន្ថែមនៃប្រលាយដែលមានស្រាប់(ខ្សែទី៤ខ/line4b) ក្រុងកំពតប៉ុណ្ណោះ។

## ១. តើគម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS2) ជាគម្រោងអ្វី?

រាជរដ្ឋាភិបាលកម្ពុជាបានទទួលប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់គម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS2) ក្រោមប្រាក់កម្ចីលេខ ៣៣១៤-CAM ។ គម្រោងនេះមានគោលបំណងពង្រឹងសមត្ថភាពប្រកួតប្រជែងនៃច្រករបៀងសេដ្ឋកិច្ចនៃមហាអនុតំបន់មេគង្គ (GMS) តាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធបរិស្ថានទីក្រុងដែលបានជ្រើសរើសនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម។ គម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀង GMS2 គឺជាផ្នែកមួយនៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ (GMS) ដែលផ្តល់អាទិភាពនិងផ្តោតលើការអភិវឌ្ឍច្រករបៀងដើម្បីភ្ជាប់ប្រទេសនិងតំបន់ទាំងនេះនៅក្នុងប្រទេសជាមួយគ្នា ដើម្បីលើកកម្ពស់និងសម្រួលដល់ពាណិជ្ជកម្ម ទេសចរណ៍ និងការវិនិយោគ។

វិសាលភាពនៃគម្រោងនេះត្រូវបានបែងចែកជា៤អនុគម្រោងនៃការងារស៊ីវិល (CW) រួមមាន៖ (១) CW01 - អនុគម្រោងប្រព័ន្ធប្រមូលនិងប្រព្រឹត្តកម្មសំអាតទឹកកខ្វក់ (WWCT) និងការងារប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុងកំពត (២) CW02 - អនុកម្រោងគ្រប់គ្រងសំណល់រឹងក្រុងកំពត (៣) CW03 - អនុគម្រោងការងារប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុងព្រះសីហនុ និង (៤) CW04 - អនុកម្រោងគ្រប់គ្រងសំណល់រឹងក្រុងព្រះសីហនុ ព្រមជាមួយនឹងការកសាងសមត្ថភាពពីការត្រួតពិនិត្យការអនុវត្តគម្រោង (PISCB) ដោយទីប្រឹក្សាបច្ចេកទេស។ ទោះជាយ៉ាងនេះក្តីអនុគម្រោងគម្រោងក្រុងព្រះសីហនុ (CW03 និង CW04) ត្រូវបានលុបចោលនៅក្នុងឆ្នាំ២០១៩ ហើយមូលនិធិនេះត្រូវបានដាក់បញ្ចូលទៅឱ្យក្រុងកំពតវិញ។

ក្រសួងសាធារណៈការ និងដឹកជញ្ជូន (MPWT) គឺជាភ្នាក់ងារប្រតិបត្តិសម្រាប់អនុវត្តគម្រោង GMS2 នេះ តាមរយៈអង្គភាពគ្រប់គ្រងគម្រោង (PMU) ហើយអង្គភាពអនុវត្តគម្រោង (PIU) គឺជាមន្ទីរសាធារណការនិងដឹកជញ្ជូន (PDPWT) ក្រុងកំពត។ ប្រាក់កម្ចីនេះត្រូវបានអនុម័តនៅថ្ងៃទី១៣ ខែវិច្ឆិកាឆ្នាំ២០១៥ ហើយត្រូវបានប្រកាសប្រសិទ្ធភាពនៅថ្ងៃទី២៦ ខែកុម្ភៈឆ្នា២០១៦។ កាលបរិច្ឆេទបិទប្រាក់កម្ចីដើមគឺថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ប៉ុន្តែត្រូវបានពន្យារជាបន្តបន្ទាប់រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣។

## ២. តើទលូផលនៃគម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS2) មានអ្វីខ្លះ?

គម្រោងនេះនឹងផ្តោតលើការកែលម្អសេវាកម្មក្រុងនៃខេត្តកំពត ដោយរួមបញ្ចូលនូវ៖ (១) ការអភិវឌ្ឍ និងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន (SLEDPs) (២) ការរចនា និងការសាងសង់ត្រូវបានអនុវត្តជាអាទិភាពចំពោះការវិនិយោគហេដ្ឋារចនាសម្ព័ន្ធក្រុង (៣) ការអភិវឌ្ឍសមត្ថភាពស្ថាប័នសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ និង (៤) ការធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងរបស់សហគមន៍ទាក់ទងនឹងសកម្មភាពគម្រោង និងនិរន្តរភាពបរិស្ថាន។ លទ្ធផលរំពឹងទុកនៃគម្រោងនឹងធ្វើឱ្យប្រសើរឡើងនូវ ហេដ្ឋារចនាសម្ព័ន្ធក្រុង និងបង្កើនភាពធន់នឹងអាកាសធាតុនៅក្នុងក្រុងកំពត។ ភាពធន់នឹងអាកាសធាតុនឹងត្រូវបានពង្រឹងស្របតាម " 3A" នៃសេដ្ឋកិច្ចបរិស្ថាន និងសមធម៌ដូចដែលមានចែងនៅក្នុងផែនការប្រតិបត្តិការក្រុងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

## ៣. តើអនុគម្រោងនិងសមាសធាតុនៃគម្រោង GMS2 ក្រុងកំពតមានអ្វីខ្លះ?

បច្ចុប្បន្នអនុគម្រោងក្នុងក្រុងកំពត មានចំនួន៣៖ (១) អនុគម្រោងប្រព័ន្ធប្រមូលនិងសំអាតទឹកកខ្វក់ (២) អនុគម្រោងប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុង និង (៣) អនុគម្រោងគ្រប់គ្រងសំណល់រឹង។ អនុគម្រោង (១) និង (២) ត្រូវបានរួមបញ្ចូលគ្នានៅក្នុងកញ្ចប់កិច្ចសន្យា CW01 លើប្រព័ន្ធប្រមូល និងសំអាតទឹកកខ្វក់ និងប្រព័ន្ធលូរំដោះទឹកភ្លៀងក្នុង។

(១) អនុគម្រោងប្រព័ន្ធប្រមូលនិងសំអាតទឹកកខ្វក់ និង (២) អនុគម្រោងប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុង ត្រូវបានសាងសង់ក្នុងគោលបំណងដើម្បីញែកទឹកកខ្វក់ហើយបន្សុទ្ធនៅអាងប្រព្រឹត្តកម្មទឹកកខ្វក់ (WWTP) ដែលសាងសង់ថ្មី ។ ប្រព័ន្ធប្រមូលទឹកកខ្វក់ គឺជាប្រព័ន្ធញែកទឹកកខ្វក់មកពីបីតំបន់គ្របដណ្តប់សំណង់ធំៗក្នុងក្រុង។ អនុគម្រោងប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុង (UD) នឹងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធលូរំដោះទឹកភ្លៀងក្នុងក្រុងដោយផ្តោតលើផ្លូវយុទ្ធសាស្ត្រមួយចំនួននៅក្នុងក្រុង និងជុំវិញតំបន់សំខាន់ដែលបានសាងសង់នៅផ្នែកខាងកើតនៃក្រុងកំពត។ ប្រវែងសរុបនៃប្រព័ន្ធលូរំដោះទឹកភ្លៀង គឺ ៧.៣៩០ម៉ែត្រ រួមទាំងបណ្តាញលូដែលនឹងហូរចូលព្រែកកំពត។ គិតត្រឹមខែមិថុនា ឆ្នាំ២០២១ ការងារសាងសង់នៃអនុគម្រោង CW01 កំពុងដំណើរការបាន ៤០% ។

ការងារស្ថិតនៅក្រោមអនុគម្រោង CW01 លើប្រឡាយលេខ៤ខ (line4b) រួមមានការកែលំអប្រឡាយដោយកាយដីក្នុងប្រឡាយដែលមានស្រាប់ដើម្បីបង្កើនសមត្ថភាពលំហូរទឹក និងកាត់បន្ថយការជន់លិចនៅពេលមានភ្លៀងធ្លាក់ខ្លាំង។ ប្រឡាយខ្សែទី៤ខ (line 4b) ត្រូវបានតភ្ជាប់ដីសើម (ទីតាំងស្ថានីយ៍បូមទឹកមេ) ដែលមានទីតាំងស្ថិតនៅខាងក្រោយក្រុងនៃខាងកើតនិងនិរតីទៅខាងលិចមុននឹងហូរចាក់ចូលទៅព្រែកកំពត។ ប្រឡាយខ្សែទី៤ខ (line4b) នឹងឆ្លងកាត់ភូមិចំនួន៤ គឺ៖ ភូមិសុវណ្ណសាគរក្នុងសង្កាត់កំពង់កណ្តាល ភូមិក្រាំងក្នុងសង្កាត់ក្រាំងអំពិល ភូមិត្រពាំងធំក្នុងឃុំត្រពាំងធំ និងភូមិកំពង់កណ្តាលក្នុងឃុំជុំគ្រៀល។

អនុគម្រោង CW01 ដំណាក់កាលទី១ (VO1) ជាការងារបន្ថែមរួមមាន៖ ការរុះរើបង្គោលបេតុងដែលនៅសេសសល់ និងផ្នែកផ្សេងទៀតនៃរចនាសម្ព័ន្ធដែលនៅតែស្ថិតនៅតាមបណ្តោយ ឬខាងក្នុងប្រឡាយ ឬនៅលើច្រាំង និងសំណល់ផ្ទះដែលបានរុះរើពីមុននៅក្រោមផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) នៃប្រឡាយខ្សែទី៤ខ (line4b)។ រចនាសម្ព័ន្ធដែលនៅសេសសល់ទាំងនេះត្រូវបានរួមបញ្ចូលក្នុងការវាស់វែងវាយតម្លៃលម្អិត (DMS) និងការសិក្សាថ្លៃដើមជំនួស (RCS) ហើយត្រូវបាន ផ្តល់សំណងទាំងស្រុងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR)។ លើសពីនេះដើមចាកត្រូវបានគេកាប់កំឡុងពេលឈូសឆាយប្រឡាយប៉ុន្តែនេះមានឥទ្ធិពលតិចតួចចំពោះលំហូររលូននៃទឹកនៅក្នុងប្រឡាយដោយសារតែឫសរបស់វាមិនត្រូវបានគាស់រំលើងយកចេញហើយធ្វើឲ្យដើមចាកដុះលូតលាស់មកវិញយ៉ាងលឿន។ ក្នុងពេលជាមួយគ្នានេះ ក៏មានការសម្អាតសំរាមក្នុងប្រឡាយផងដែរ។ ការងារនេះមិនមានការធ្វើលទ្ធកម្មដី ឬមានផលប៉ះពាល់ដោយអចេតនា (IR) បន្ថែមទេ ក្រៅពីការរុះរើរចនាសម្ព័ន្ធដែលបានកំណត់ពីមុន ហើយក៏បានទូទាត់សងនៅក្នុងរបៀបនៃផលប៉ះពាល់ (COI)។ ការងារទាំងនេះភាគច្រើនត្រូវបានបញ្ចប់រួចរាល់ហើយ។

សម្រាប់អនុគម្រោង CW01 ដំណាក់កាល៣ (VO3) លើការស្តារឡើងវិញនូវប្រឡាយខ្សែទី៤ខ (line4b) ដែលមានស្រាប់ (ពីបឹងចាកទៅព្រែកកំពត) ការរចនាប្រឡាយឡើងវិញបានធ្វើឡើងនៅឆ្នាំ២០២០-២០២១។ បន្ទាប់ពីការវិភាគប្រព័ន្ធធារា សាស្ត្រពេញលេញ

នៃប្រព័ន្ធលូរំដោះទឹកក្នុងក្រុងកំពត ការងារជួសជុលប្រឡាយខ្សែទី៤ខ (line4b) ឡើងវិញ ត្រូវបានគេចាត់ទុកថាចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពដឹកជញ្ជូននិងប្រសិទ្ធភាពរួមនៃប្រឡាយ និងលុបបំបាត់ការជាំបន្លែច្រើនហួសប្រមាណនៅលើប្រឡាយ ទប់ស្កាត់ការបាក់ច្រាំងប្រឡាយ និងផ្នែកខ្លះនៃប្រឡាយដែលមានទឹកនៅទ្រឹង។ ការងារនេះនឹងរួមបញ្ចូលទាំងការដេកសម្ភារៈដែលមិនសមស្របចេញពីគែមប្រឡាយ ចាក់បេតុងនូវផ្នែកខ្លះនៃប្រឡាយ និងការសាងសង់ផ្លូវសេវខាងប្រឡាយ (ទទឹង ២,៤ ម៉ែត្រ)។ មើលឧបសម្ព័ន្ធ១ សម្រាប់ព័ត៌មានលម្អិតអំពីទីតាំងនៃការងារ និងផ្នែកឆ្លងកាត់។

(៣) អនុគម្រោងគ្រប់គ្រងសំណល់រឹង កំពុងសាងសង់ទីលានចាក់សំរាមថ្មីមួយ ស្ថិតលើដីទំហំ១៩ ហិចតា ដែលបានបានធ្វើលទ្ធកម្មដោយផ្អែកលើគោលការណ៍ "ទិញតាមតម្លៃកំណត់របស់អ្នកលក់" ។ ការសាងសង់អនុគម្រោង CW01 កំពុងដំណើរការដោយមានវឌ្ឍនភាព ៤៨% គិតត្រឹមខែមិថុនា ឆ្នាំ២០២១។

## ៤. តើការធ្វើលទ្ធកម្មដីនិងការងារដោះស្រាយផលប៉ះពាល់ និងផលប៉ះពាល់បណ្តោះអាសន្នរបស់គម្រោងមានវិសាលភាពអ្វីខ្លះ?

ប្រឡាយខ្សែទី៤ខ (line4b) ទាំងមូលមានប្រវែង១.១៧៣.២៧ ម² ជាដីរដ្ឋ និងដីកសិកម្មឯកជន ១.៥០៦.២០ម² ហើយមានខ្នងផ្ទះសរុបចំនួន១១ ដែលមានទំហំ ៤១១.៤៩ម² ជាកម្មសិទ្ធិរបស់គ្រួសាររងផលប៉ះពាល់ចំនួន១១ (AHs) ឬអ្នករងផលប៉ះពាល់ចំនួន៤៦ នាក់ (APs)។ ប្រាំបួន (៩) នៃដប់មួយ (១១) ខ្នងផ្ទះដែលរងផលប៉ះពាល់ខ្លាំង (AHs) ឬអ្នករងផលប៉ះពាល់ខ្លាំង (Aps) ចំនួន៣៩ នាក់ បានរុះរើចេញទាំងស្រុង ហើយខ្នងផ្ទះដែលរងផលប៉ះពាល់ (AHs) ផ្នែកខ្លះៗមានចំនួនពីរ (២) ឬអ្នករងផលប៉ះពាល់ (Aps) ផ្នែកខ្លះៗមានចំនួន៧នាក់។ ខ្នងផ្ទះដែលរងផលប៉ះពាល់ (Ahs) ទាំង៩ នេះត្រូវបានកំណត់ថាគ្មានដីហើយត្រូវបានផ្លាស់ប្តូរទីលំនៅទៅកន្លែងថ្មី។ ផ្អែកលើលទ្ធផលនៃការវាស់វែងវាយតម្លៃលម្អិត (DMS) និងការទូទាត់សំណងបញ្ចប់ មានខ្នងផ្ទះរងផលប៉ះពាល់ (AHs) ចំនួន៣១ មានសិទ្ធិទទួលបានសំណងជាដី ចំពោះប្រភេទសំណង់ទី១ (លំនៅដ្ឋាន/primary structure) ប្រភេទសំណង់បន្ទាប់សំណង់ (second structure) និងសំណង់ផ្សេងទៀត និងដើមឈើ។ ខ្នងផ្ទះដែលរងផលប៉ះពាល់ (AHs) ចំនួន៩ មានសិទ្ធិទទួលបានកម្មវិធីស្តារប្រាក់ចំណូល។

ក្នុងចំណោមរចនាសម្ព័ន្ធដែលរងផលប៉ះពាល់គ្រប់ប្រភេទ នៅតែមានសំណល់រឹងនៃរចនាសម្ព័ន្ធដែលជាបង្គោលនិងផ្នែកផ្សេងទៀតនៃរចនាសម្ព័ន្ធបន្សល់ទុកនៅតាមបណ្តោយ ឬនៅខាងក្នុងប្រឡាយ ឬនៅតាមច្រាំងព្រែកដែលខ្នងផ្ទះរងផលប៉ះពាល់ (AHs) បានទុកចោលបន្ទាប់ពីពួកគេរុះរើចេញ និងផ្លាស់ប្តូរទីលំនៅរួច ឬផ្លាស់ប្តូរមកវិញក្នុងកំឡុងឆ្នាំ ២០២០ ។ កិច្ចការដែលនៅសល់នឹងត្រូវបានយកចេញទាំងស្រុងក្នុងកំឡុងពេលប្របតិបត្តិការងារបន្ថែមរបស់អនុគម្រោង CW01/VO3 (ដំណាក់កាលទី៣)។

ផលប៉ះពាល់នៃប្រឡាយខ្សែទី៤ខ (line4b) មិនមានផលប៉ះពាល់បឋម (IR) នៅសល់ទេ។ រចនាសម្ព័ន្ធថ្មីមួយចំនួនត្រូវបានសាងសង់បន្ទាប់ពីកាលបរិច្ឆេទប្រកាសឱសានវាទនៃការកំណត់ផលប៉ះពាល់ សំណង់ទាំងនេះនឹងត្រូវបានយកចេញដោយគ្មានការទូទាត់សំណងណាមួយឡើយ។ គ្មានផលប៉ះពាល់បណ្តោះអាសន្នត្រូវបានរំពឹងទុក។

## ៥. តើដីចំណីផ្លូវ និងរបៀងនៃផលប៉ះពាល់នៃអនុគម្រោងជាអ្វី?

នៅក្នុងប្រទេសកម្ពុជា ដីចំណីផ្លូវសំដៅដល់ដីរបស់រដ្ឋនៅតាមបណ្តោយផ្លូវដែលមានចម្ងាយជាក់លាក់ពីអ័ក្សប្រឡាយ និងផ្លូវដែលមានស្រាប់សម្រាប់ការអភិវឌ្ឍនាពេលអនាគត។ ដីនៅតាមដីចំណីផ្លូវ គឺជាដីដែលគ្រប់គ្រងដោយរដ្ឋ ឬរបស់រដ្ឋាភិបាល។ របៀងនៃផលប៉ះពាល់ គឺជាតំបន់ដែលបានស្នើសុំសម្រាប់អនុវត្តការងារស្តារហេដ្ឋារចនាសម្ព័ន្ធឡើងឡើងវិញ។ ដីចំណីផ្លូវនៃប្រឡាយខ្សែទី៤ខ (line4b) មានប្រវែង៧ម មួយខាង ពីទំនប់ប្រឡាយ អត្ថន័យនៃដីចំណីផ្លូវប្រែប្រួលអាស្រ័យទៅនឹងទទឹងប្រឡាយ។ របៀបនៃផលប៉ះពាល់ (COI) សម្រាប់ការងារដើមសម្រាប់ប្រឡាយខ្សែទី៤ខ (line4b) គឺ ប្រវែង៧ម ពីអ័ក្ស (បន្ទាត់កណ្តាល) ប្រឡាយ បើដូច្នេះដីចំណីផ្លូវពេញលេញរបស់ប្រឡាយកំណត់ដោយមិនគិតពីទទឹងប្រឡាយដែលមានស្រាប់នៅទីតាំងណាមួយឡើយ។

## ៦. តើថ្ងៃប្រកាសឱសានវាទនៃសិទ្ធិទទួលបានសំណងជាអ្វី?

ថ្ងៃប្រកាសឱសានវាទ (COD) គឺជាកាលបរិច្ឆេទដែលកំណត់ឡើងដោយរដ្ឋាភិបាលកម្ពុជា ដែលបង្កើតនូវសិទ្ធិទទួលបាននៃគ្រួសារ / ប្រជាពលរដ្ឋរងផលប៉ះពាល់ សម្រាប់ទទួលបានសំណង និងជំនួយផ្សេងៗនៅក្រោមអនុគម្រោងនេះ។ មានតែប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងតំបន់នៃរបៀងនៃផលប៉ះពាល់ ឬបាត់បង់ទ្រព្យសម្បត្តិមុនពេលថ្ងៃឱសានវាទប៉ុណ្ណោះ នឹងមានសិទ្ធិទទួលបានសំណងនិងជំនួយ។ ជនណាដែលកាន់កាប់ដី ឬសាងសង់សំណង់បន្ថែម ឬកែលម្អផ្ទះសម្បែងរបស់ខ្លួនបន្ទាប់ពីថ្ងៃឱសានវាទ នឹងមិនមានសិទ្ធិទទួល បានសំណងឡើយ។ ទ្រព្យសម្បត្តិផ្សេងៗ ដូចជាសំណង់ដែលបានសាងសង់ (ថ្មី ឬពង្រីកបន្ថែមលើសំណង់មានស្រាប់) ដំណាំដើមឈើហូបផ្លែ និងទ្រព្យសម្បត្តិប្រហាក់ប្រហែលផ្សេងទៀតបន្ទាប់ពីថ្ងៃឱសានវាទនឹងមិនត្រូវបានទទួលសំណងទេ។ ប្រជាពលរដ្ឋរងផលប៉ះពាល់នូវរបៀងនៃផលប៉ះពាល់បន្ទាប់ពីទទួលបានការទូទាត់សំណងនឹងចាំបាច់ត្រូវតែរើចេញដើម្បីអនុញ្ញាតឱ្យការងារសាងសង់អាចអនុវត្តបាន។

ថ្ងៃប្រកាសឱសានវាទ (COD) សម្រាប់អនុគម្រោងគឺថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ ដែលជាកាលបរិច្ឆេទដែលត្រូវនឹង IOL និងការការធ្វើជំរឿនពេញលេញនៃចំនួនប្រជាពលរដ្ឋរងផលប៉ះពាល់ក្នុងដំណាក់កាលរៀបចំគម្រោងជំនួយបច្ចេកទេស (PPTA)។

## ៧. វិធានការដែលបានអនុម័តដើម្បីចៀសវាងនិងកាត់បន្ថយផលប៉ះពាល់ និងការដោះស្រាយផលប៉ះពាល់

ក្រុមវិស្វករបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកជំនាញដោះស្រាយផលប៉ះពាល់ ដើម្បីពិនិត្យមើលពីសារតានៃប្រព័ន្ធប្រឡាយ និងធ្វើការរចនាយ៉ាងណាដើម្បីកុំឲ្យមានផលប៉ះពាល់ IR បន្ថែម។ វិធានការខាងក្រោមនេះត្រូវបានអនុម័តដើម្បីចៀសវាងផលប៉ះពាល់នៃការតាំងលំនៅថ្មីសម្រាប់អនុគម្រោង CW01/VO3 លើការស្តារឡើងវិញនូវប្រឡាយខ្សែទី៤ខ (line4b) ដែលមានស្រាប់ (ពីបឹងចាកទៅព្រែកកំពត)៖

- របៀបនៃផលប៉ះពាល់ COI ត្រូវបានរៀបចំឡើងវិញដើម្បីចៀសវាងផលប៉ះពាល់ដល់ហាងកាហ្វេនៅចំណុចច្រកចេញពីប្រឡាយទៅព្រែក។
- របៀបនៃផលប៉ះពាល់ COI ត្រូវបានបង្រួមតូចនៅទីតាំងផ្ទះប្រជាពលរដ្ឋនៅជាប់ប្រឡាយ (នៅលើដីចំណីផ្លូវ) ជញ្ជាំងទ្រនាប់ត្រូវបានសម្រេចចិត្តឲ្យសាងសង់ ហើយផ្លូវចូលរួមតូច២ម រវាងប្រឡាយ និងផ្ទះ។ មិនមានផលប៉ះពាល់ IR លើផ្ទះទេ។

## ៨. តើនិតីវិធីសម្រាប់សំណង និងសិទ្ធទទួលបានមានអ្វីខ្លះ?

សំណងគឺផ្អែកលើលទ្ធផលនៃការវាស់វែងលម្អិត (DMS)។ ការវាស់វែងលម្អិត គឺជាការស្ទង់មតិលម្អិត និងធ្វើការវាស់វែងនូវទ្រព្យសម្បត្តិដែលរងនូវផលប៉ះពាល់ដោយរួមបញ្ចូលដីធ្លី ផ្ទះ សំណង់ ដំណាំ និងដើមឈើរបស់គ្រួសារទាំងអស់ដែលរងនូវផលប៉ះ ពាល់។ ការងារនេះ ត្រូវបានអនុវត្តនៅចន្លោះខែធ្នូ ឆ្នាំ២០២១៨ ដល់ខែមករា ២០១៩។ ការវាស់វែងលម្អិត (DMS) ត្រូវបានធ្វើឡើងជាមួយខ្នងផ្ទះប៉ះពាល់ (AH) ម្តងមួយៗ ដើម្បីកត់ត្រា និងសុំការយល់ព្រមលើការខាតបង់ទាំងអស់របស់ខ្នងផ្ទះដែលរងផលប៉ះពាល់។

អនុគម្រោង CW01 អាងប្រព្រឹត្តកម្ម (WWTP) កំពត និងការងារប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងអនុគម្រោង CW02 ទីលានចាក់ សំរ៉ាមកំពត ត្រូវបានគ្របដណ្តប់នៅក្នុងផែនការដោះស្រាយផលប៉ះពាល់ (RP) ដំបូងនៃគម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS2) សម្រាប់អនុគម្រោងក្រុងកំពតខែសីហា ឆ្នាំ២០២១៥។ ផែនការដោះស្រាយផលប៉ះពាល់នេះ (RP) ត្រូវបានធ្វើបច្ចុប្បន្នភាពតាមកាលកំណត់ដោយផ្អែកលើការរចនាវិស្វកម្មលម្អិត (DED) ការវាស់វែងលម្អិត (DMS) និងការស្ទង់មតិសេដ្ឋកិច្ចសង្គម (SES) ការពិគ្រោះយោបល់ជាសាធារណៈជាច្រើនដងជាមួយខ្នងផ្ទះដែលរងផលប៉ះពាល់ (Ahs) និង ការសិក្សាថ្លៃដើមជំនួស (RCS). ផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) ត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី នូវថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩។ ឯកសាររឹងនៃផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) បានដំកល់ទុកនៅអង្គភាពគ្រប់គ្រងគម្រោង (PMU) អង្គភាពអនុ

វត្តគម្រោង (PIU) សង្ខាត់ និងឯកសារទន់ដំកល់នៅលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB[1] website)។

គ្រួសារ/ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយគម្រោងនេះមានសិទ្ធិទទួលបានសំណងសម្រាប់ទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ក្រោមគោលការណ៍សំណងសំខាន់ៗដូចខាងក្រោម៖

- ការផ្តល់ជូននូវសំណងអោយបានត្រឹមត្រូវ និងយុត្តិធម៌ ជាមុន
- ការផ្តល់ជូនសំណងអោយបានពេញលេញអោយបានរួចរាល់ជា មុនសិន មុនពេលអនុវត្តការរុះរើរ និង
- ការទូទាត់សំណង គឺត្រូវពឹងផ្អែកលើការសិក្សាអត្រាតម្លៃជំនួស សម្រាប់ទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ ស្របតាមតម្លៃទីផ្សារ ដែលបានកំណត់ដោយក្រុមការងារទីប្រឹក្សាឯករាជ្យ តាមរយៈការសិក្សាថ្លៃដើមជំនួស (RCS) ដោយគ្មានការកាត់កងណាមួយ សម្រាប់ការរំលោះសម្ភារៈសង្គ្រោះ និងថ្លៃប្រតិបត្តិការ។

សិទ្ធិទទួលបាន គឺត្រូវបានរៀបរាប់យ៉ាងពិស្តានៅក្នុងម៉ាទ្រីសនៃសិទ្ធិចុងក្រោយនៅក្នុងផែនការដោះស្រាយផលប៉ះពាល់លម្អិត (DPR)។ ការបង្ហាញពកញ្ចប់សំណងទៅដល់គ្រួសារដែលរងផលប៉ះពាល់ដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR) ក្នុងកំឡុងពេលចរចាកិច្ចសន្យានៅថ្ងៃទី ២៨ ខែវិច្ឆិកាឆ្នាំ ២០១៩។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR) បានបញ្ចប់ការទូទាត់សំណង ១០០% ក្នុងតម្លៃជំនួសពេញលេញយោងតាមផែនការដោះស្រាយផលប៉ះពាល់លំអិត (DRP) ដែលបានអនុម័តនៅថ្ងៃទី៩ ខែមករា ឆ្នាំ ២០២០ ចំពោះផលប៉ះពាល់នៅក្នុងរបៀបនៃផលប៉ះពាល់ (COI) ដូចដែលបានរៀបរាប់លម្អិតនៅក្នុងផែនការដោះស្រាយផលប៉ះពាល់លំអិត (DRP)។

## ៩. តើរបៀបនៃការគណនាអត្រាតម្លៃជំនួសសម្រេចធ្វើឡើង និងទូទាត់សំណងដោយរបៀបណាដែរ?

ការចំណាយសម្រាប់ការទូទាត់សំណង គឺពឹងផ្អែកទៅលើតម្លៃទៅទីផ្សារ ឬ អត្រាតម្លៃជំនួសនៃទ្រព្យសម្បត្តិដែលបានបាត់បង់ ដោយមិនមានការកាត់កងអ្វីទាំងអស់សម្រាប់តម្លៃសម្ភារៈ ការរំលោះ ឬតម្លៃដើម។ ការសិក្សាតម្លៃដើមជំនួស (RCS) គឺត្រូវបានអនុវត្ត ដោយទីប្រឹក្សាឯករាជ្យដែលមានសមត្ថភាពក្នុងស្រុក។ ទីប្រឹក្សានឹងធ្វើការវិភាគលម្អិតអំពីអត្រាទីផ្សារចំពោះទ្រព្យសកម្មគ្រប់ប្រភេទដែលមាននៅក្នុងគម្រោង ឬតំបន់អនុគម្រោង និងរៀបចំអត្រាឯកតាសម្រាប់ប្រភេទទ្រព្យនីមួយៗដែលនឹងរងផលប៉ះពាល់។ ទាំងនេះត្រូវបានប្រើប្រាស់ដើម្បីគណនាតម្លៃជំនួស និងដើម្បីរៀបចំថវិការសម្រាប់ផែនការដោះស្រាយផលប៉ះពាល់។ ការសិក្សាអត្រាតម្លៃជំនួស ត្រូវបានបញ្ចប់នៅក្នុងខែមេសា ឆ្នាំ២០១៩ សម្រាប់អនុគម្រោង។

## ១០. តើអ្វីទៅជាការវិភាគនៃការងារសាងសង់?

ការងារសាងសង់ អនុគម្រោង CW01៖ ប្រព័ន្ធប្រមូលទឹកកខ្វក់ និងប្រព្រឹត្តកម្មទឹកកខ្វក់ និង ប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុងត្រូវបានចុះកិច្ចសន្យានៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ហើយការងារសាងសង់បានចាប់ផ្តើមនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។ ក្រុមហ៊ុនម៉ៅការការងារសាងសង់គឺ SBPH ENGINEERING & CONSTRUCTION CO., LDT. JV I ENGINEERING (GROUP) CO., LTD. CAMBODIA.

ការងារបន្ថែមស្ថិតនៅក្រោមអនុគម្រោង CW01/VO3 នឹងចាប់ផ្តើមការងារសាងសង់នាចុងឆ្នាំ២០២១ និងបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០២២។

## ១១. តើខ្ញុំមានសិទ្ធក្នុងការប្តឹងតវ៉ាអំពីការមិនពេញចិត្ត ឬមិនយល់ព្រមចំពោះបញ្ហាសំណង ការដោះស្រាយផលប៉ះពាល់ ឬបញ្ហាដែលទាក់ទងផ្សេងៗ ទៀតបានទេ? ប្រសិនបើអាច តើតាមរបៀបណាខ្លះ?

[1] https://www.adb.org/projects/documents/cam-46443-002-rp

បាទ/ចាស គឺបាន, អ្នកមានសិទ្ធក្នុងការដាក់នូវពាក្យបណ្តឹងទៅ កាន់គណៈ កម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) ប្រសិនបើអ្នកមិនច្បាស់ ឬមិនសប្បាយចិត្តជាមួយនឹងសកម្មភាពដោះស្រាយផលប៉ះពាល់។ សមាជិកគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា រង់ចាំជួយដល់អ្នកបានគ្រប់ពេលទាំងអស់។ ការព្យាយាមជួយដោះស្រាយបណ្តឹងតវ៉ារបស់អ្នកគឺចាប់ផ្តើមពីថ្នាក់ភូមិតាមរយៈមេភូមិ។ ទោះជាយ៉ាងណាក៏ដោយអ្នកអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ទៅកាន់សមាជិកណាម្នាក់នៃគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) (ឧទាហរណ៏៖ ភូមិ ស្រុក និងថ្នាក់ខេត្ត ឬក្រុមការងារដោះស្រាយផលប៉ះពាល់)។ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) នឹងកត់ត្រាទុកនូវរាល់ឯកសារបណ្តឹងតវ៉ារបស់អ្នក និងធ្វើការណែនាំអ្នកអំពីដំណោះស្រាយ (សូមមើលទំនាក់ទំនងព័ត៌មាន លម្អិតនៅខាងក្រោម)។

## ១២.តើនរណាដែលខ្ញុំអាចទាក់ទងបានក្នុងករណីដែលខ្ញុំត្រូវការបញ្ជាក់/បំភ្លឺ ឬមានបញ្ហា/បណ្តឹងតវ៉ាអ្វីមួយ?

គម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS2) ត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួងនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) បានបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) ស្ថិតក្រោមគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា នៅថ្នាក់ភូមិ ស្រុក និងខេត្ត។ គណៈកម្មាធិការទាំងនេះ ត្រូវបានធ្វើប្រតិបត្តិការមុនពេលចាប់ផ្តើមការវាស់វែងលម្អិត (DMS) ។ រាល់បណ្តឹង ឬការតវ៉ានានាដែលទាក់ទងនឹងការវាស់វែងលម្អិតមិនត្រឹមត្រូវ ឬកញ្ចប់ថវិកាសំណង នឹងត្រូវបានបញ្ជូនទៅកាន់គណៈកម្មាធិការ ដើម្បីស្វែងរកដំណោះស្រាយ។ ឈ្មោះបុគ្គលសំខាន់ៗ និងលេខ ទូរស័ព្ទទំនាក់ទំនងមានបញ្ជាក់ក្នុងប្រអប់ខាងក្រោម សម្រាប់បំភ្លឺអំពីបញ្ហាបច្ចេកទេស និងបណ្តឹងដែលពាក់ព័ន្ធនឹងគម្រោង៖

**ក. បញ្ហាពាក់ព័ន្ធនឹងនិដ្ឋភាពបច្ចេកទេស និងការងារសាងសង់**

(i) លោក **ពូ ម៉ានិត** មន្ត្រីគ្រប់គ្រងគម្រោង (PMU) អង្គភាពគ្រប់គ្រងគម្រោង ក្រសួងសាធារណការ និងដឹកជញ្ជូន ភ្នំពេញ ទូរស័ព្ទលេខ 012 803 203

(ii) លោក **ឌុច ចន្ថារ៉ា** ប្រធានការិយាល័យអន្តរវិស័យនៃសាលាក្រុង អនុប្រធាន អង្គភាពអនុវត្តគម្រោង (PIU) ក្រុងកំពត
ទូរស័ព្ទលេខ 012 449 536

(iii) លោក **រម្យ សុវិទ្យា** តំណាងអ្នកទទួលកិច្ចសន្យាម៉ៅការសាងសង់
ទូរស័ព្ទលេខ 069 532 456

**ខ. បញ្ហាពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់**

(i) លោក **ឃួន ដាវិត** នាយករង អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភ្នំពេញ
លេខទូរស័ព្ទ 012 831 977

**ឧបសម្ព័ន្ធ១ - ផែនទី និងរូបភាព**

រូបភាពទី១: ទីតាំងអនុគម្រោងប្រព័ន្ធប្រមូលទឹកកខ្វក់ និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ និងប្រព័ន្ធលូរំដោះទឹកភ្លៀងក្រុងកំពត



រូបភាពទី២: ទីតាំងប្រឡាយខ្សែទី៤ខ (line 4b)



រូបភាពទី៣: ប្រភេទប្រឡាយខ្សែទី៤ខ (Line 4b) ផ្នែកឆ្លងកាត់ Cross-Section



**ឧបសម្ព័ន្ធ២ - ទម្រង់យន្តការដោះស្រាយសំណាង** Grievance Redress Mechanism Forms

## ទម្រង់បែបបទពាក្យបណ្តឹងបុគ្គល

## គម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងនៃមហាអនុតំបន់ទន្លេមេគង្គ ( GMS2 )

| | | |
|---|---|---|
| កាលបរិច្ឆេទបណ្តឹង | | លេខ DMS |
| ឈ្មោះអ្នកដាក់ពាក្យបណ្តឹង | | |
| លេខអត្តសញ្ញាណប័ណ្ណ<br>សៀវភៅគ្រួសារ | | |
| លេខទំនាក់ទំនង | | |
| អាសយដ្ឋាន | | |
| សេចក្តីសង្ខេបនៃពាក្យបណ្តឹង | | |
| បញ្ជីឯកសារគាំទ្រ / ភស្តុតាង | | |

ឈ្មោះ: (មេគ្រួសារ)

ហត្ថលេខា/ស្នាមមេដៃ:

កាលបរិច្ឆេទ:

# ការចុះពាក្យបណ្តឹង

## គម្រោងទី២នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរៀងនៃមហាអនុតំបន់ទន្លេមេគង្គ ( GMS2 )

ក្រុង-ស្រុក-ខណ្ឌ: ______________________________

រាជធានី-ខេត្ត: ________________________________

| កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង | ករណីលេខ | ឈ្មោះនិងអត្តសញ្ញាណប័ណ្ណអ្នកដាក់ពាក្យបណ្តឹង | | ចំណុចសំខាន់នៃពាក្យបណ្តឹង |
|---|---|---|---|---|
| | | ឈ្មោះ | អត្តសញ្ញាណបណ្ណសៀវភៅគ្រួសារ/ | |
| | | | | |
| | | | | |
| | | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---------

## លិខិតពីរអភិបាលខណ្ឌ-ស្រុក

ក្រុង-ស្រុក-ខណ្ឌ: ______________________________

រាជធានី-ខេត្ត: ______________________________

<table>
<tr><td colspan="6" align="center">បណ្តឹងបុគ្គល</td></tr>
<tr><td colspan="3">ករណីលេខៈ</td><td colspan="3"></td></tr>
<tr><td colspan="3">ឈ្មោះអ្នកដាក់ពាក្យបណ្តឹង</td><td colspan="3"></td></tr>
<tr><td colspan="3">កាលបរិច្ឆេទបណ្តឹង</td><td colspan="3"></td></tr>
<tr><td colspan="6" align="center">សេចក្តីសង្ខេបនៃពាក្យបណ្តឹង<br>(ដូចគ្នានឹងពាក្យសុំចុះឈ្មោះបណ្តឹងតវ៉ាម្នាក់ៗ)</td></tr>
<tr><td colspan="6"></td></tr>
<tr><td colspan="6" align="center">កិច្ចប្រជុំគណៈកម្មការដោះស្រាយបណ្តឹងតវ៉ា</td></tr>
<tr><td colspan="2">កាលបរិច្ឆេទ:</td><td colspan="2">ម៉ោង:</td><td colspan="2">ទីតាំង:</td></tr>
<tr><td colspan="3">អ្នកចូលរួម</td><td colspan="3"></td></tr>
<tr><td colspan="3">សេចក្តីសង្ខេបនៃការពិភាក្សា</td><td colspan="3"></td></tr>
<tr><td colspan="3">កាលបរិច្ឆេទនៃការចុះពិនិត្យទីតាំង (ប្រសិនបើមាន)</td><td colspan="3"></td></tr>
</table>

| លទ្ធផលនៃការប្រជុំ/សេចក្តីសម្រេច |
|---|
| |
| បដិសេធ -គ្មានមូលដ្ឋានយោងតាមតារាងនៃសិទ្ធិទទួលបានសំណង<br>សមនឹងទទួល - បណ្តឹងបញ្ជូនបន្តទៅអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដើម្បី ចាត់វិធានការ |

ឈ្មោះ:
តួនាទី:

ហត្ថលេខា/ស្នាមមេដៃ:

កាលបរិច្ឆេទ:

## Annex F: Disclosure of PIB

### F.1. Kraing Ampil commune






**F.2. Trapaing Thom commune**






**F.3. Chum Kreal commune**






**F.4. Kampong Kandal Sangkat**




